06 JUIN 2017



# ព្រះរាជក្រឹត្យ

នស/រកត/០៤១៧/៣១៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១.-** ត្រូវបានបង្កើតគោរមងារ “ **សន្តិបណ្ឌិត** ” នៃបណ្ឌិត្យសភានគរបាលកម្ពុជា សម្រាប់ផ្តល់ជូនថ្នាក់ដឹកនាំនៃក្រសួងមហាផ្ទៃ ដែលទទួលបានសញ្ញាបត្របណ្ឌិតកិត្តិយស ជំនាញនានា ក្នុងវិស័យសន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈ។

**មាត្រា២.-** ត្រូវបានតែងតាំង ថ្នាក់ដឹកនាំនៃក្រសួងមហាផ្ទៃ ដែលទទួលបានសញ្ញាបត្របណ្ឌិតកិត្តិយសជំនាញ “ **ដឹកនាំបញ្ជាកងកម្លាំងនគរបាល** ” ចំនួន **១៣រូប** ជា **សន្តិបណ្ឌិត** នៃបណ្ឌិត្យសភានគរបាលកម្ពុជា ៖

១. ឯកឧត្តម នាយឧត្តមសេនីយ៍ **ឯម សំអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

២. ឯកឧត្តម នាយឧត្តមសេនីយ៍ **តេង សាវង្ស** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

៣. ឯកឧត្តម នាយឧត្តមសេនីយ៍ **អ៊ុក គីមលេខ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

៤. ឯកឧត្តម នាយឧត្តមសេនីយ៍ **ខុល គឿន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

៥. ឯកឧត្តម នាយឧត្តមសេនីយ៍ **នេត សាវឿន** អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ

៦. ឯកឧត្តម នាយឧត្តមសេនីយ៍ **លួ រ៉ាមីន** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ

៧. ឯកឧត្តម **ហេង ហាក់** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ

៨. ឯកឧត្តម **ចាន់ អ៊ាន** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ

៩. ឯកឧត្តម នាយឧត្តមសេនីយ៍ **ម៉ៅ ប៊ុណ្ណារិន** អគ្គនាយក នៃអគ្គនាយកដ្ឋាន ភស្តុភារ និងហិរញ្ញវត្ថុ

១០.ឯកឧត្តម នាយឧត្តមសេនីយ៍ **សុខ ផល** អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍

១១.ឯកឧត្តម នាយឧត្តមសេនីយ៍ **ម៉ៅ ចន្ទ័តារា** អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

១២.ឯកឧត្តម **ខៀវ សុភ័គ** នាយកខុទ្ទកាល័យសម្តេចក្រឡាហោម

១៣.ឯកឧត្តម ឧត្តមអគ្គានុរក្សថ្នាក់លេខ១ **ចាន់ គីមសេង** អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ ។

**មាត្រា៣.-** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧*

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

នសរ.១៧០៤.៣១៤ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

លេខ: ៣២៨ ស.ណ

**សំណៅចែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**